( ១៣ )

# អនុក្រឹត្យស្តីពី

# នីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ

លេខៈ ១៥៥ អនក្រ.បក

ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៥ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទាន
## សម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយកិច្ចការផ្ទៃនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក, ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានដោយធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា១.

អនុក្រឹត្យនេះមានគោលដៅកំណត់នូវគោលការណ៍ និងនីតិវិធីនៃការអនុវត្តកិច្ចប្រតិបត្តិការចំណាយថវិការដ្ឋ តាមរយៈការផ្តល់ប្រាក់បុរេប្រទាននៅក្នុងក្របខ័ណ្ឌចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ ។

មាត្រា២.

អនុក្រឹត្យនេះមានគោលបំណងដើម្បីឱ្យអាណាប័កក្រសួង ស្ថាប័ន ៖

- ពង្រឹងការគ្រប់គ្រងចំណាយប្រាក់បុរេប្រទាន ឱ្យប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព
- យកចិត្តទុកដាក់ក្នុងការធ្វើនិយ័តកម្ម (ការទូទាត់) ប្រាក់បុរេប្រទានឱ្យបានឆាប់រហ័ស
- កាត់បន្ថយការស្នើសុំប្រាក់បុរេប្រទាននៅក្នុងចំណាយថវិកាចរន្ត ឱ្យទៅជាការអនុវត្តចំណាយតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

មាត្រា៣.

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័នដែលមានថវិកាកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។

## ជំពូកទី ២
## គោលការណ៍សំខាន់ៗនៃការផ្តល់ប្រាក់បុរេប្រទាន

មាត្រា៤.

ការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ អនុវត្តសម្រាប់មុខចំណាយទាំងឡាយមានជាអាទិ៍ដូចខាងក្រោម ៖

ក. ចំណាយចរន្ត ៖

- ចំណាយសម្រាប់ទទួលគណៈប្រតិភូបរទេស
- ចំណាយសម្រាប់ប្រជុំ សិក្ខាសាលា និងសន្និសីទ
- ចំណាយសម្រាប់ពិធីបុណ្យប្រពៃណី បុណ្យជាតិ និងអន្តរជាតិ
- ចំណាយសម្រាប់ការប្រឡងប្រជែង
- ចំណាយសម្រាប់ការបំប៉នសិស្សពូកែ និងកីឡាករ
- ចំណាយសម្រាប់ការប្រកួតកីឡា
- ចំណាយសម្រាប់សម្ភោធសមិទ្ធផលនានា
- ចំណាយជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន និងធារាសាស្ត្រ ដែលត្រូវអនុវត្តដោយអង្គភាពរដ្ឋ

ខ. ចំណាយវិនិយោគ ៖

- ចំណាយសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ ដែលត្រូវអនុវត្តដោយអង្គភាពរដ្ឋ ។

មាត្រា៥.

ការអនុវត្តការផ្តល់ប្រាក់បុរេប្រទានសម្រាប់មុខចំណាយទាំងឡាយដូចបានកំណត់ក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះក្រសួង ស្ថាប័នត្រូវគោរពទៅតាមគោលការណ៍ទាំងឡាយ ដូចខាងក្រោមនេះ ៖

ក. ចំណាយចរន្ត ៖

- ត្រូវមានឥណទានថវិកាសល់ទំនេរ សម្រាប់កាត់ទុកដើម្បីធ្វើការទូទាត់ចំណាយ
- ត្រូវលើកសំណើសុំប្រាក់បុរេប្រទាន ដោយមានភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតទៅតាមអនុកណនីនីមួយៗឱ្យបានច្បាស់លាស់ និងមានភ្ជាប់សលាកបត្រកក់ក្រោចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីកាត់ទុកឥណទានថវិកាសម្រាប់ធ្វើអាណត្តិនិយ័តកម្ម ។
- ត្រូវធ្វើការទូទាត់ប្រាក់បុរេប្រទានលើកមុនទៅតាមពេលវេលាកំណត់សិន ទើបអាចលើកសំណើសុំប្រាក់បុរេប្រទានលើកក្រោយបាន លើកលែង

តែការចំណាយប្រាក់បុរេប្រទានលើកមុន ត្រូវប្រើពេលវេលាយូរលើសពីមួយខែឡើងទៅ ។

- ក្នុងករណីដាយថាហេតុណាមួយធ្វើឱ្យប្រាក់បុរេប្រទានឆ្នាំមុនមិនបានទូទាត់ ត្រូវកាត់ទុកឥណទានថវិកាឆ្នាំបន្ទាប់ជាមុនសិន ហើយត្រូវរៀបចំធ្វើការទូទាត់ឱ្យបានជ្រះស្រឡះមុននឹងចាប់ផ្ដើមប្រតិបត្តិការថវិកា ។
- មិនអនុញ្ញាតប្រើប្រាស់បុរេប្រទានសាច់ប្រាក់ បើគ្មានឥណទានថវិកាគ្រប់គ្រាន់ទេនោះ ។

ខ. ចំណាយថវិកាវិនិយោគ ៖

- ត្រូវអនុវត្តផ្ដល់ប្រាក់បុរេប្រទាន សម្រាប់គម្រោងក្នុងក្របខ័ណ្ឌនៃកញ្ចប់ឥណទានអនុញ្ញាតប្រចាំឆ្នាំ ។ ក្នុងករណីការអនុវត្តគម្រោង ឬការបំពេញនីតិវិធីសម្រាប់គម្រោងមានការយឺតយ៉ាវ ដែលធ្វើឱ្យការទូទាត់បុរេប្រទានមិនអាចធ្វើទាន់ក្នុងឆ្នាំ ត្រូវកាត់ទុកឥណទានថវិកាឆ្នាំបន្ទាប់ ដើម្បីធ្វើការទូទាត់ស្មើនឹងចំនួនប្រាក់មិនទាន់ទូទាត់នៃគម្រោងទាំងមូល ។
- ត្រូវមានភ្ជាប់មកជាមួយសំណើសុំបុរេប្រទាន នូវគម្រោងចំណាយលម្អិត លើកលែងតែក្នុងករណីចាំបាច់ត្រូវអនុវត្តបន្ទាន់ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដែលគម្រោងចំណាយលម្អិតមិនអាចធ្វើបានភ្លាមៗ ដោយសារស្ថានភាពទីតាំង ឬកាលៈទេសៈមិនអំណោយផល ។
- ក្នុងករណីមានការចាំបាច់តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដែលត្រូវផ្ដល់ប្រាក់បុរេប្រទានសម្រាប់អនុវត្តគម្រោងក្នុងក្របខ័ណ្ឌនៃឥណទានឆ្នាំបន្ទាប់ ក្រសួង-ស្ថាប័នត្រូវកាត់ទុកកញ្ចប់ឥណទាននៃឆ្នាំបន្ទាប់សម្រាប់អនុវត្តគម្រោងនេះ ។

មាត្រា៦.

ចំពោះការផ្ដល់ប្រាក់បុរេប្រទានសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ ដែលហិរញ្ញប្បទានដោយដៃគូរអភិវឌ្ឍន៍ត្រូវអនុវត្តតាមស្មារតីអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។

---

មាត្រា៧.

ការអនុវត្តផ្ដល់ប្រាក់បុរេប្រទានតាមរយៈមូលប្បទានបីត្រសម្រាប់ចំណាយទៅចូលរួមការប្រជុំអាស៊ាននៅបរទេស ត្រូវឆ្លងកាត់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

ដើម្បីកាត់ទុកឥណទានថវិកា សម្រាប់ធ្វើការទូទាត់ក្រោយពេលគណៈប្រតិភូវិលត្រឡប់ពីបរទេសវិញ ។

## ជំពូកទី ៣
## កិច្ចដំណើរការនៃការផ្តល់ប្រាក់បុរេប្រទាន

មាត្រា៨.

ចំពោះការចំណាយទិញសម្ភារៈបរិក្ខារសម្រាប់ការប្រឡងប្រជែង ការប្រកួតកីឡា និងពិធីផ្សេងៗដែលមានចំនួនទឹកប្រាក់ចាប់ពី ហាសិបលានរៀល ឡើងទៅ មិនអនុញ្ញាតឱ្យធ្វើការផ្តល់បុរេប្រទានថវិកាទេ ។ ក្រសួង-ស្ថាប័នត្រូវលើកសំណើសុំធានាចំណាយដោយឡែកដើម្បីអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ហើយការចេញអាណត្តិបើកប្រាក់ក្រោយពីការប្រគល់-ទទួលទំនិញតាមកិច្ចសន្យា ។

មាត្រា៩.

ការផ្តល់ប្រាក់បុរេប្រទាន ( ឬការផ្តល់ថវិកាមួយចំនួនមុនសម្រាប់ចំណាយដំណើរការ ) ទាំងឡាយដូចបានកំណត់នៅក្នុងមាត្រា ៤ ត្រូវអនុវត្តដូចខាងក្រោមនេះ ÷

- ចំពោះចំណាយចរន្ត ត្រូវផ្តល់ថវិកាសម្រាប់ចំណាយដំណើរការមុនចំនួន ៦០% នៃទឹកប្រាក់ដែលត្រូវផ្តល់បុរេប្រទាន ។ លើកលែងគម្រោងសម្រាប់ចំណាយជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធារាសាស្ត្រ ការផ្តល់ថវិកាសម្រាប់ចំណាយដំណើរការមុនត្រឹម ៤០% ។
- ចំពោះចំណាយថវិកាវិនិយោគ ត្រូវផ្តល់ប្រាក់បុរេប្រទានមិនលើសពី ៤០% នៃទឹកប្រាក់គម្រោងសម្រាប់ចំណាយវិនិយោគសាធារណៈ ។

មាត្រា១០.

ក្នុងករណីចំណាយប្រាក់បុរេប្រទាន ដែលទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ សំណង់ និងសេវាត្រូវតែអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈដែលមានចែងជាធរមាន ។

មាត្រា១១.

អាណាប័កនៃក្រសួង ស្ថាប័ននានា ដែលបានបញ្ជាចំណាយថវិការបស់ខ្លួនតាមរយៈការផ្តល់ប្រាក់បុរេប្រទាននៅក្នុងក្របខ័ណ្ឌចំណាយថវិកាចរន្ត និង ចំណាយថវិកាវិនិយោគសាធារណៈ ចាំបាច់ត្រូវបំពេញឱ្យបានគ្រប់គ្រាន់ និង

ត្រឹមត្រូវដោយឡើយលក្ខណ៍អក្សរនូវ " សលាកប័ត្រគណនេយ្យភាពហិរញ្ញវត្ថុ " ដើម្បីអមភ្ជាប់មកជាមួយនូវសំណើសុំប្រើប្រាស់សាច់ប្រាក់របស់ថវិកាជាតិតាមរយៈរបភាពបុរេប្រទាននេះ ។

សលាកប័ត្រគណនេយ្យភាពហិរញ្ញវត្ថុខាងលើ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ៤
## កិច្ចនិយ័តកម្មនៃប្រាក់បុរេប្រទាន

**មាត្រា១២.**

អាណាប័កគ្រប់ក្រសួង ស្ថាប័ន ត្រូវចាត់តាំងរដ្ឋទេយ្យករដែលមានស្រាប់ដើម្បីឱ្យទទួលបន្ទុកបន្ថែមក្នុងការតាមដានចំណាយថវិកា និងទទួលខុសត្រូវក្នុងការប្រមូលលិខិតយុត្តិការចំណាយថវិកា (សក្ខីប័ត្រចំណាយ) សម្រាប់រៀបចំធ្វើអាណត្តិនិយ័តកម្ម និងអាណត្តិបើកប្រាក់បង្គ្រប់ទៅតាមចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងលិខិតបុរេប្រទានថវិកា ។

**មាត្រា១៣.**

រាល់លិខិតយុត្តិការចំណាយ ត្រូវមានចុះហត្ថលេខាបញ្ជាក់ទទួលស្គាល់ពីភាពត្រឹមត្រូវរបស់អាណាប័ក ឬមន្ត្រីដែលមានការប្រគល់សិទ្ធិជំនួស ។

**មាត្រា១៤.**

នីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទាន ដូចមានបទប្បញ្ញត្តិចែងក្នុងមាត្រាទាំងឡាយនៃអនុក្រឹត្យនេះ ត្រូវមានការណែនាំលម្អិតសម្រាប់អនុវត្តជាក់ស្តែងដោយសារាចរ ឬប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា១៥.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៦.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អាជ្ញាធរសវនកម្ម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៦ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ